# សិលាចារឹករកឃើញថ្មីនៅភូមិក្រសាំង ខេត្តកំពង់ធំ

ភូមិក្រសាំង មានទីតាំងស្ថិតនៅក្នុងឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលជាទីតាំងស្ថិតនៅតាមបណ្តោយផ្លូវបុរាណភ្ជាប់ពីតំបន់ប្រាសាទសំបូរព្រៃគុក ឆ្ពោះទៅកាន់តំបន់អង្គរ (កាត់តាមកំពង់ក្តី) ហើយនៅក្នុងតំបន់នោះសម្បូណ៌ដោយបុរាណដ្ឋានជាច្រើនកន្លែង។ សិលាចារឹករកឃើញថ្មីភូមិក្រសាំងដែលលើកយកមករៀបរាប់នៅក្នុងអត្ថបទនេះ សព្វថ្ងៃរក្សាទុកនៅក្នុងចេតិយឯកជនមួយកន្លែង ហើយរូបខ្ញុំផ្ទាល់ក៏មិនធ្លាប់បានឃើញសិលាចារឹកនេះផ្ទាល់ដែរ ពោល គឺខ្ញុំទទួលបានរូបថតសិលាចារឹកនេះពីលោក ហែម ថៃល។ តើសិលាចារឹករកឃើញនៅភូមិក្រសាំង ខេត្តកំពង់ធំមានអត្ថន័យ និងខ្លឹមសារយ៉ាងណាខ្លះ?

សិលាចារឹកនេះ ចារឹកឡើងជាភាសាខ្មែរមានចំនួន ២ ជ្រុង ដែលជ្រុងទី១ មានអក្សរចំនួ១៧ បន្ទាត់ និងជ្រុងទី២ មានអក្សរចំនួន ១៨ បន្ទាត់ ដោយចារឹកលើថ្មភក់មានរាងជាស្ទឹកសីមា។ យើងមិនមានរូបភាពណាមួយដែលមានគុណភាពច្បាស់ល្អដើម្បីអានសិលាចារឹកនេះទេ។ ប៉ុន្តែ បើយើងពិនិត្យទៅលើគោរម្យងាររបស់ព្រះមហាក្សត្រ ដែលបានលើកនៅក្នុងខ្លឹមសារសិលាចារឹកពោល គឺ "កម្រតេង កំតួន អញ" អាចបង្ហាញឱ្យយើងដឹងថា សិលាចារឹកនេះទំនងសាងនៅស.វ.ទី១១ ក្នុងរជ្ជកាលរបស់ព្រះបាទស្រីសូរ្យវរ្ម័នទី១ (គ.ស.១០០២ ដល់ ១០៤៩)។ ផ្នែកដំបូងរបស់ចារឹកនេះចាប់ផ្តើមឡើងដោយការប្រាប់កាលបរិច្ឆេទ ប៉ុន្តែផ្នែកខាងស្តាំនៃកាលបរិច្ឆេទនេះបានរលុបអក្សរបាត់ទៅហើយ ពោល គឺនៅសល់ត្រឹមតែពាក្យថា "សក" ដែលចង់បញ្ជាក់អំពីឆ្នាំសាច់រឿង ឬឆ្នាំដែលគេចារសិលាចារឹកនេះឡើង។

សិលាចារឹកនេះ ជាប្រភេទព្រះរាជសាសន៍ (ព្រះរាជឱង្ការត្រាស់បង្គាប់ ឬសេចក្តីណែនាំ) របស់ព្រះបាទសូរ្យវរ្ម័នទី១ (ព្រះបាទកម្រតេងកំតួនអញស្រីសូរ្យវម៌្មទេវ) ត្រាស់បញ្ជាដល់មន្ត្រីរបស់ទ្រង់ ដើម្បីចុះទៅអភិវឌ្ឍន៍ ឬចេញរាជានុគ្រោះដល់ទេវស្ថាន។ ទ្រង់បានចេញរាជានុគ្រោះដល់ដីភូមិស្រុកមួយ ដែលជាដីភូមិធ្លាប់ទទួលបានសេចក្តីអនុគ្រោះការប្រទានតាំងពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ (ព្រះបាទកម្រតេងកំតួនអញស្តេចយាងទៅបរមេស្វរ) មកម៉្លេះ ដោយគោរពតាម និងធ្វើដូចអ្វីដែលធ្លាប់ទទួលបានក្នុងរាជ្យព្រះរាជាអង្គមុនដែរ។ ព្រះបាទស្រីសូរ្យវរ្ម័នទី១ បានបង្គាប់ដល់ព្រះសភា (ប្រធានតុលាការ) ឱ្យដាក់ដីភូមិនោះមិនស្ថិតនៅក្រោមចំណុះមន្ត្រីភ្នាក់ងាររាជការខាងប្រមូលពន្ធអាករស្រូវ ប្រេង ឬអភិបាលខេត្តនៅទីនោះឡើយ។ ដីភូមិដែលបានទទួលព្រះរាជានុគ្រោះពីព្រះរាជាអាចមានសិទ្ធិពេញលេញក្នុងការប្រមូល និងទទួលផលឱ្យរួចផុតពីពន្ធអាករទាំងឡាយ។ ព្រះបាទស្រីសូរ្យវរ្ម័នទី១ ទ្រង់នឹងដាក់ទោសទណ្ឌ (និណ្ឌ័យ) ដល់ជនទាំងឡាយណា

អត្ថបទដោយ៖ កំ វណ្ណារ៉ា

ដែលហ៊ានល្មើសមិនគោរពនិងអនុវត្តតាមព្រះរាជបញ្ញត្តិ ហើយទ្រង់បានត្រាស់បញ្ជាមន្ត្រីថ្នាក់ក្រោមបោះបង្គោលសីមាព្រំដីឱ្យបានត្រឹមត្រូវ ដោយក្នុងនោះមានកំណត់ព្រំគោលសីមាថែមទៀតផង ទាំងទិសខាងលិច ខាងជើង ខាងត្បូង និងខាងកើត។

## អត្ថបទពាក្យចារឹក

### ជ្រុងទី១

១. ..................គក នុ មាន [វ្រះគាសន ]
២. [ធូលី វ្រះ ] បាទ ធូលី [ជេង៑ វ្រះ ]
៣. [កម្រតេង៑ កំត្វ ]ន៑ អញ៑ ត ...........
៤. ...............វ្រះ ក ..................
៥. .............ការ នុ ភូ[មិ] ..............
៦. ...................តាញ៑ យោក
៧. ..................ច នុ ម្រតាញ៑ ..
៨. .....................នុ ម្រតាញ៑
៩. ........................ក្លុម្កប
១០. [ក្ស ].....អាចាយ៌្យ វ្រះ ស
១១. [ភា]..........វ្រះបាទ កម្រតេង៑
១២. .............ត ស្តច៑ ទៅ បរមេ
១៣. [គ្វរ] ........វ្រះករុណា ប្រសាទ ស្រុ
១៤. [កិ].......................ភូមិ លេង៑ វ្នំ អាច្ឆិ
១៥. ...................ខ្លោញ៑ វិគែយ វ្នំ អាច្ឆិ
១៦. .............កិ នុ ចញ៑ចូល ផោង
១៧. វ្នំ អាច្ឆិ អាយត្វ ត ខ្លោញ៑ ស្រូ វ្នំ អាច្ឆិ

### ជ្រុងទី២

១. ..ស្រុ វ្រិហិ វ្នំ អាច្ឆិ ទារ ច
២. ញ្ជូល ផោង្វ៑ វ្នំ អាច្ឆិ អាយត្វ ត ខ្លោ
៣. ញ៑ ភូតាគ បយ៌្យង៑ .....ខ្លោ
៤. ញ៑ វិគែយ នុ ខ្លោញ៑ ស្រុ នុ
៥. ខ្លោញ៑ ភូតាគ បយ៌្យង៑ ១ ត វ្នំ ថ្វៃ

អត្ថបទដោយ៖ កំ វណ្ណារ៉ា

៦. តោយ៑ ពោះហ វ្រះ គាសន មនិ
៧. វ្រះបាទ កម្រតេង៑ កំត្ងន៑ អញ
៨. [ត រាជ្យ ស្តច] ទៅ បរមេឝ្វរ បន្ទូល្ល បិ
៩. ........តោយ៑ ប្រេ អាចាយ៌្យ វ្រះ ស
១០. [កា]......វលិ បង្គំ ថ្ប្វង៑ និវេទន
១១. ត វ្រះបាទ កម្រតេង៑ កំត្ងន៑ អញ
១២. ប្រេ និណ៌្ណយ.............
១៣. បាត្តិម ជំន្ស ................
១៤. ហលតោ[យ] ឧត្តរ
១៥. ..ចិ ល្វះហ ត គិ ............ត គិ
១៦. ត្រវាង៑ ទៅ ឧត្តរ ................ប្វ
១៧. រ្វំ លោះ ត គិ ត្រវាង៑ ម្រតាញ ប
១៨. រ តោយ៑ ទាក្សិន អចិន ត្រវាង៑ ប្រ

## *បំណកប្រែ*

## *ផ្ទុងទី១*

*(បន្ទាត់ទី១ ដល់ ១៧)៖ នៅក្នុងឆ្នាំ ..... ស.ក. ព្រះមហាក្សត្រទ្រង់មានព្រះរាជសាសន៍ (រាជឱង្ការត្រាស់បង្គាប់ ឬសេចក្តីណែនាំ) ធូលីព្រះបាទធូលីជើងព្រះកម្រតេងកំត្វនអញ ទ្រង់មានសេចក្តីតម្រាស់ដល់ .... ព្រះ ....និងដីភូមិ ... [ម្រតាញ] យក ... និងម្រតាញ .... និងម្រតាញ ..... ខាងខែរនោច អាចារ្យ ព្រះសកា ..... ព្រះបាទកម្រតេងអញ ..... ដែលព្រះអង្គស្តេចបានយាងទៅកាន់បរមេស្វរ (ព្រះបាទស្រីជ័យវរ្ម័នទី២) ហើយ ..... ព្រះអង្គទ្រង់មានសេចក្តីសណ្តោសករុណាប្រទានស្រុក .... ដីភូមិ ដោយមិនឱ្យស្ថិតនៅ .... ក្រោមចំណុះ ខ្លោញវិសយ (អភិបាលខេត្ត) មិនអាច ..... និងចញ្ចូល (ប្រេង) ផង ដោយមិនស្ថិតនៅក្រោមចំណុះខ្លោញស្រូវ មិនចំណុះក្រោម.....។*

## *ផ្ទុងទី២*

*(បន្ទាត់ទី១ ដល់ ៥)៖ មិនចំណុះក្រោម ខ្លោញស្រូវ (វ្រិហិ មានន័យថា ស្រូវ) ដោយមិនអាចដើម្បីទទួលចញ្ចូលផង (ចញ្ចូល មានន័យថា ប្រេង) ដោយមិនស្ថិតនៅក្រោមចំណុះខ្លោញកូតាស (អ្នកដកហូតពន្ធអាករ) ប្រេង .... ខ្លោញវិសយ និងខ្លោញស្រូវ និងខ្លោញកូតាស ប្រេង។*

*(បន្ទាត់ទី៥ ដល់ ១៨)៖ បើជនណាមិនគោរពអនុវត្តធ្វើតាមព្រះរាជឱង្ការណែនាំរបស់ព្រះបាទកម្រតេងកំត្វនអញ... រាជស្តេចដែលទ្រង់យាងទៅកាន់បរមេស្វរ ព្រះអង្គបានមានបន្ទូល*

ប្រើដើម្បី....ដោយប្រើអាចារ្យព្រះសភា..... បានចូលបង្គំក្រាបថ្វាយសូមស្នើដល់ព្រះបាទកម្រតេង កំត្វនអញ ត្រាស់បង្គាប់ប្រើនិណ្ណ៌យ (ដាក់ទោស) ..... ខាងលិច ជំនៀ ..... ខាងជើង.... រហូតដល់ ..... គឺត្រពាំង ទៅខាងជើង.... ខាងកើត រហូតដល់ត្រពាំងម្រតាញ បរ ខាងត្បូង អចិន ត្រពាំងប្រ។

សរុបជារួមមក សិលាចារឹករកឃើញថ្មីនៅភូមិក្រសាំង ខេត្តកំពង់ធំ គឺជាព័ត៌មានថ្មីមួយ បន្ថែមពីលើទិន្នន័យចាស់ ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នយោបាយរបស់ព្រះបាទស្រីសូរ្យវរ្ម័នទី១ ដែលជាស្តេចដ៏ល្បីល្បាញនៅក្នុងប្រវត្តិសាស្ត្រខ្មែរ។ លើសពីនេះ សិលាចារឹកនេះ ក៏ផ្តល់ព័ត៌មាន ឱ្យយើងបានដឹងខ្លះៗអំពីព្រឹត្តិការណ៍នយោបាយរបស់ព្រះបាទជ័យវរ្ម័នទី២ទៀតផង។ ចំណុច ទាំងនេះនាំឱ្យយើងដឹងថា បើទោះបីព្រះបាទស្រីសូរ្យវរ្ម័នទី១ មិនជាប់ស្រឡាយជាមួយព្រះបាទ ស្រីជ័យវរ្ម័នទី២ ក៏ដោយ ក៏ទ្រង់នៅតែបង្ហាញការគោរពដល់ព្រះរាជាអង្គមុនយ៉ាងខ្ជាប់ខ្ជួន។





រូបលេខ១ និងលេខ២៖ សិលាចារឹករកឃើញថ្មីនៅភូមិក្រសាំង (ចារឹកលើថ្មគោលសងខាង)

ប្រភព៖ ហែម ថៃល

អត្ថបទដោយ៖ កំ វណ្ណារ៉ា